# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងពាណិជ្ជកម្ម**
**អគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម**
**នាយកដ្ឋានគោលនយោបាយពាណិជ្ជកម្ម**

លេខៈ ៣១៤ គនព

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ២០១៧

**កំណត់បង្ហាញ**

**សូមគោរពជូន**

**ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម**

**តាមរយៈ:** -ឯកឧត្តមអគ្គនាយកជំរុញពាណិជ្ជកម្ម
-ឯកឧត្តមរដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម

**កម្មវត្ថុ:** សំណើសុំពិនិត្យ និងចុះហត្ថលេខា លើសេចក្តីព្រាងប្រកាស ស្តីពី លក្ខខណ្ឌតម្រូវហាឡាលកម្ពុជា សម្រាប់ភោជនីយដ្ឋាន និងអាហារដ្ឋាន។

**យោង:** ខ្លឹមសារនៃកិច្ចប្រជុំលើកទី២ និងលើកទី៣ របស់គណៈកម្មាធិការត្រួតពិនិត្យផលិតផលហាឡាលកម្ពុជា។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមគោរពជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបថាៈ កាលពីថ្ងៃទី១០ និងថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៧ កន្លងទៅ លេខាធិការដ្ឋាននៃគណៈកម្មាធិការត្រួតពិនិត្យផលិតផលហាឡាលកម្ពុជា បានរៀបចំកិច្ចប្រជុំ សមាសភាពគណៈកម្មាធិការអន្តរក្រសួង ដើម្បីពិនិត្យ និងពិភាក្សា លើសេចក្តីព្រាងប្រកាសស្តីពី លក្ខខណ្ឌតម្រូវហាឡាលកម្ពុជា សម្រាប់ភោជនីយដ្ឋាន និងអាហារដ្ឋាន។ ជាលទ្ធផល អង្គប្រជុំបានផ្តល់ធាតុចូល ពិនិត្យ និងឯកភាពបញ្ចប់សេចក្តីព្រាងប្រកាស ស្តីពី លក្ខខណ្ឌតម្រូវហាឡាលកម្ពុជា សម្រាប់ភោជនីយដ្ឋាន និង អាហារដ្ឋាន ដូចបានភ្ជាប់ជូនមកជាមួយ។ លេខាធិការដ្ឋានកិច្ចការហាឡាលកម្ពុជា សូមគោរពស្នើសុំសេចក្តីសម្រេចពី **ឯកឧត្តមរដ្ឋមន្ត្រី** និងសូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាចុះហត្ថលេខាលើប្រកាសដូចបាន ជូនភ្ជាប់មកជាមួយដោយអនុគ្រោះ។

សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

**ប្រធាននាយកដ្ឋាន**

**គិត តារ៉ា**

**មតិថ្នាក់អគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម**

28.7.2017

**មតិឯកឧត្តមរដ្ឋលេខាធិការទទួលបន្ទុក**

01.08.17 THORA